## អាជ្ញាធរអគ្គិសនីកម្ពុជា

អាជ្ញាធរអគ្គិសនីកម្ពុជាគឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលសិទ្ធិពីរាជរដ្ឋាភិបាលនិងមានស្វ័យភាព ក្នុងការត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី និងការគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី។ អាជ្ញាធរអគ្គិសនីកម្ពុជា បង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

## ១.សមត្ថកិច្ចទទួលខុសត្រូវក្នុងវិស័យអគ្គិសនីរបស់ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលជាអ្នកទទួលខុសត្រូវគ្រប់គ្រងវិស័យអគ្គិសនីទាំងមូល។ ក្រសួងមានសមត្ថកិច្ចរៀបចំនិងគ្រប់គ្រងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងស្តង់ដា បច្ចេកទេស សុវត្ថភាពនិង បរិស្ថាននៃវិស័យអគ្គិសនី ។

អាជ្ញាធរអគ្គិសនីកម្ពុជា ជាអ្នកទទួលខុសត្រូវគ្រប់គ្រងសកម្មភាព នៃការធ្វើសេវាកម្មនិងការប្រើប្រាស់អគ្គិសនី។ អាជ្ញាធរមានសមត្ថកិច្ចចេញដកហូតឬព្យួរអាជ្ញាប័ណ្ណសំរាប់ការធ្វើសេវាកម្មអគ្គិសនី ព្រមទាំងជាអ្នកកំណត់ថ្លៃសេវាចេញបញ្ញតិ ធ្វើការត្រួតពិនិត្យ ដាក់ពិន័យ និង ដោះស្រាយវិវាទពាក់ព័ន្ធនឹងការផ្តល់សេវានិងការប្រើប្រាស់អគ្គិសនី។

### ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- គោលនយោបាយថាមពល
- យុទ្ធសាស្ត្រវិស័យអគ្គិសនី
- ផែនការអភិវឌ្ឍន៍វិស័យអគ្គិសនី
- ស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថានក្នុងវិស័យអគ្គិសនី
- ការងារផ្សេងៗ

### អាជ្ញាធរអគ្គសនីកម្ពុជា

- ដាក់បញ្ញតិ និងចេញអាជ្ញាប័ណ្ណឱ្យការធ្វើសេវាកម្មអគ្គិសនី
- កំណត់ថ្លៃលក់អគ្គិសនី,ពិនិត្យថ្លៃដើម
- សម្របសម្រួលដោះស្រាយវិវាទ
- ត្រួតពិនិត្យ ដាក់ពិន័យអ្នកធ្វើសេវាកម្ម និងអ្នកប្រើប្រាស់កុំឱ្យខុសច្បាប់

## ២.សិទ្ធិអំណាចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

មាត្រា៧នៃច្បាប់ស្តីអគ្គិសនីបានផ្តល់**សិទ្ធិអំណាចសំខាន់ៗចំនួន ១៥ ចំនុច** ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាដូចខាងក្រោម :

១- ចេញ កែសំរួល ព្យួរ ដកហូតឬបដិសេធអាជ្ញាប័ណ្ណសំរាប់ការផ្គត់ផ្គង់ សេវាកម្មអគ្គិសនី

២- អនុម័តថ្លៃ និងបន្ទុកចំណាយផ្សេងៗព្រមទាំងល័ក្ខខ័ណ្ឌនៃសេវាកម្ម អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ

៣-កំណត់ឱ្យអនុវត្តបញ្ញត្តិ បែបបទនិងស្តង់ដាសំរាប់កម្មវិធីវិនិយោគ របស់អ្នកកាន់អាជ្ញាប័ណ្ណ

៤-ពិនិត្យឡើងវិញលើសកម្មភាពហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធសហគ្រាស របស់អ្នកកាន់អាជ្ញាប័ណ្ណ

៥- អនុម័ត និងដាក់ឱ្យអនុវត្តស្តង់ដាប្រតិបត្តិសំរាប់អ្នកកាន់អាជ្ញាប័ណ្ណ

៦- វាយតំលៃ និងសំរុះសំរួលបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ និងវិវាទកិច្ចសន្យាដែលពាក់ព័ន្ធនឹងអ្នកកាន់អាជ្ញាប័ណ្ណ

៧- អនុម័ត និងដាក់ឱ្យប្រតិបត្តិនូវប្រព័ន្ធគណនីឯកភាពសំរាប់អ្នកកាន់អាជ្ញាប័ណ្ណទាំងអស់

៨- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍លើវិស័យអគ្គិសនី និងពត៌មានពាក់ព័ន្ធនានា

៩- កំណត់កំរៃនានាដែលត្រូវអនុវត្តលើអ្នកកាន់អាជ្ញាប័ណ្ណ

១០-កំណត់បែបបទផ្តល់ពត៌មានដល់សាធារណជន អំពីកិច្ចការក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាតម្លាភាព

១១-ចេញបញ្ញត្តិ និងបទបញ្ជាសមស្របព្រមទាំងបញ្ជាផ្អាកជាបណ្តោះអាសន្ន ឬជាស្ថាពរចំពោះសេវាកម្មអគ្គិសនី

១២-ពិន័យជាប្រាក់ ផ្អាកការប្រើប្រាស់អគ្គិសនី ព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ចំពោះការរំលោភលើច្បាប់នេះ និងលិខិតបទដ្ឋាននានា ព្រមទាំងបញ្ញត្តិផ្សេងៗទៀត របស់អាជ្ញាធរអគ្គិសនីកម្ពុជា

១៣-តំរូវឱ្យអ្នកធ្វើសេវាកម្ម និងអ្នកប្រើប្រាស់អគ្គិសនី គោរពប្រតិបត្តិនូវវាល់វិធាន ដែលទាក់ទងនឹងសន្តិសុខ ថាមពល សេដ្ឋកិច្ច បរិស្ថាន របស់ប្រទេសជាតិ ព្រមទាំងគោលនយោបាយដទៃទៀតរបស់រាជរដ្ឋាភិបាល

១៤-ចាត់វិធានការផ្សេងទៀតចំពោះបញ្ហាបន្ទាប់បន្សំ ឬដែលជាផលវិបាកស្តែងចេញពីមុខងារដូចបានរៀបរាប់ខាងលើនេះ និង

១៥-បង្កើតល័ក្ខខ័ណ្ឌជ្រើសរើស និងប្រើប្រាស់មន្ត្រី ឬបុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងជំនាញការឬទីប្រឹក្សា ។

## ៣.រចនាសម្ព័ន្ធគ្រប់គ្រងការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា




អាជ្ញាធរអគ្គិសនីកម្ពុជាសំរេចនិងអនុម័តបញ្ហាគន្លឹះសំខាន់ៗតាមរយៈការពិនិត្យនិងការបោះឆ្នោត នៅក្នុងសម័យប្រជុំ។ ដូច្នេះសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា គឺជាអង្គការសំរេចការងារខ្ពស់បំផុតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ មាត្រា ២១នៃច្បាប់ស្តីពីអគ្គិសនីបានកំណត់ថាសមាជិកទាំងអស់របស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវមានសំឡេងក្នុងការបោះឆ្នោតលើរាល់បញ្ហាដែលតំរូវឱ្យមានការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ការអនុម័តនេះត្រូវផ្អែកលើសំឡេងភាគច្រើន ។

## ៤. សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា

អាជ្ញាធរអគ្គិសនីកម្ពុជាមានសមាជិកទាំងអស់៣រូបដែលក្នុងនោះមានមួយរូបជាប្រធាន។ ប្រធាននិងសមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា តែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។ សមាជិកនិមួយៗមានអាណត្តិ៣ (បី) ឆ្នាំហើយត្រូវបញ្ចប់ក្នុងពេលខុសៗគ្នា លើកលែងតែក្នុងអាណត្តិដំបូង។ ប្រធានមានឋានៈស្មើនឹងរដ្ឋលេខាធិការ សមាជិកដទៃទៀតមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។ សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវចូលនិវត្តន៍នៅពេលអាយុ៦០ (ហុកសិប) ឆ្នាំ។

## ៥. បេសកកម្មរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

អាជ្ញាធរអគ្គិសនីកម្ពុជាមានបេសកកម្មដូចខាងក្រោម:

១- បង្កើតបរិយាកាសដ៏សមរម្យស្រប និងគតិយុត្តិមួយក្នុងវិស័យអគ្គិសនីនៅកម្ពុជាសំរាប់ជំរុញឱ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ក្នុងការធ្វើអាជីវកម្មអគ្គិសនីជំរុញឱ្យមានការវិនិយោគដែលមានចរិកយូរអង្វែងមានប្រសិទ្ធភាព និងមានគុណភាពព្រមទាំងជំរុញ និងលើកកំពស់ផ្នែកឯកជនឱ្យដើរតួនាទីជាកំលាំងចលករនៃកំណើនសេដ្ឋកិច្ច ។

២- ការពារសិទ្ធិអ្នកប្រើប្រាស់ ដើម្បីទទួលបាននូវការផ្គត់ផ្គង់សេវាកម្មអគ្គិសនីដែលមានស្ថេរភាព គុណភាព និងគ្រប់គ្រាន់តាមតំលៃសមរម្យ ។

៣- បង្កើតឱ្យមានការប្រកួតប្រជែងនៅទីណា ដែលអាចធ្វើទៅបានក្នុងវិស័យអគ្គិសនី

៤- បង្កើតល័ក្ខខ័ណ្ឌដើម្បីឱ្យមានការផ្គត់ផ្គង់អគ្គិសនី និងការប្រើប្រាស់អគ្គិសនី ប្រព្រឹត្តទៅដោយប្រសិទ្ធភាព គុណភាព ចីរភាព និង តម្លាភាព ។

## ៦. ថវិការសំរាប់ប្រតិបត្តិការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

អាជ្ញាធរអគ្គិសនីកម្ពុជាមានថវិការស្វយ័តមួយសំរាប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។ ថវិការនេះគឺជាកំរៃដែលអ្នកសុំអាជ្ញាប័ណ្ណ និងអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា។ កំរៃនេះហៅថាកំរៃអាជ្ញាប័ណ្ណ។ កំរិតអតិបរិមានៃកំរៃអាជ្ញាប័ណ្ណកំណត់ដោយរាជរដ្ឋាភិបាល ។

ថវិការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវដាក់ដំកល់ក្នុងគណនីមួយនៅធនាគាររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ។ មានតែអាជ្ញាធរអគ្គិសនីកម្ពុជាទេ ដែលមានសិទ្ធិប្រើប្រាស់ថវិការនេះ ។

អាជ្ញាធរត្រូវរៀបចំគំរោងថវិការសំរាប់ឆ្នាំការិយបរិច្ឆេទនិមួយៗ ដែលមានកំណត់ចំណូល និងចំណាយរបស់អាជ្ញាធរ។ គំរោងនេះត្រូវកំណត់ច្បាស់លាស់នូវកំរៃអាជ្ញាប័ណ្ណសំរាប់ឆ្នាំការិយបរិច្ឆេទនិមួយៗរួមទាំងវិធីគណនាកំរៃអាជ្ញាប័ណ្ណព្រមទាំងបៀវត្សរ៍ និងប្រាក់បំណាច់ផ្សេងទៀតដែលត្រូវទូទាត់ជូនសមាជិក និងមន្ត្រីជាន់ខ្ពស់របស់អាជ្ញាធរ។ គំរោងថវិការនេះត្រូវដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។